## ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

### អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ




# ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារកម្ពុជា

## ការព្យាករណ៍អំពីការផ្គត់ផ្គង់និងតម្រូវការកម្លាំងពលកម្ម

ឆ្នាំទី ១ លេខ ១ ចេញផ្សាយ ខែមករា ឆ្នាំ ២០២០

Labour Market Information

ឆ្នាំទី ១ លេខ ១ ចេញផ្សាយខែ មករា ២០២០

# នាយកដ្ឋានព័ត៌មានទីផ្សារការងារ

## អំពីព្រឹត្តិបត្រព័ត៌មានទីផ្សារការងារ



ការបោះពុម្ពព្រឹត្តិប័ត្រព័ត៌មានទីផ្សារការងារ នឹងធ្វើជាប្រចាំ ពីរដង ក្នុងមួយឆ្នាំដើម្បីធ្វើបច្ចុប្បន្នភាពស្តីពីទីផ្សារពលកម្មកម្ពុជា។ ចំពោះ ព្រឹត្តិបត្រលេខនេះ គឺផ្តោតលើការសង្ខេបនូវរបកគំហើញ និងការស្នើរ គោលនយោបាយតាមរយៈការវិភាគ និងព្យាការណ៍កម្លាំងពលកម្ម អនាគតរបស់ប្រទេសកម្ពុជា ហើយបង្កើតជាសេនារីយូ ដោយផ្តោតលើ ការផ្គត់ផ្គង់ និងតម្រូវការការងារ។

ការស្រាវជ្រាវនេះគាំទ្រដោយមូលនិធិធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តាមរយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបច្ចេកទេស និងវិជ្ជាជីវៈ (TVETSDP) របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

លេខបន្ទាប់ និងផ្តោតលើលទ្ធផលនៃការអង្កេតវាស់វែងជំនាញ វិស័យអប់រំបណ្តុះបច្ចេកទេស និងវិជ្ជាជីវៈ។

## ក្នុងលេខនេះមាន

សារតានៃការស្រាវជ្រាវ ........ ២
ក្របខ័ណ្ឌនៃការវិភាគ ........ ៣
របកគំហើញសំខាន់ៗ ........ ៤

# សារតានៃការស្រាវជ្រាវ

ដោយមានការគាំទ្រ និងការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍ ធនធានមនុស្សប្រកបដោយគុណភាពជំនាញ និងសមត្ថភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការភ្លាមៗ និងយូរអង្វែងនៃកំណើន សេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)បានផ្តល់មូលនិធិ ដើម្បីបន្តសកម្មភាពការងាររបស់នាយកដ្ឋាន ព័ត៌មានទីផ្សារការងារ និងទីភ្នាក់ងារទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ក្នុងការព្យាករណ៍ និងវិភាគទីផ្សារការងារក្នុងប្រទេសកម្ពុជា។

គោលបំណងសំខាន់ នៃការស្រាវជ្រាវនេះគឺដើម្បីកំណត់គំរូការព្យាករណ៍ដែលបាន អនុញ្ញាតឱ្យផ្ទៀងផ្ទាត់ ភាពជាប់ទាក់ទងរវាងការចាកចេញពីប្រព័ន្ធអប់រំនិងបណ្តុះបណ្តាល វិជ្ជាជីវៈទៅនឹងតម្រូវការជំនាញ នៃទីផ្សារការងារអនាគត។

ការអនុវត្តការស្រាវជ្រាវនេះបានចាប់ផ្តើមពី ខែមេសា ដល់ ខែវិច្ឆិការឆ្នាំ២០១៩ ដោយមានការសហការរវាង NEA និង នាយកដ្ឋានព័ត៌មានទីផ្សារការងារ (DLMI) ជាមួយសកម្មភាពសំខាន់ៗដូចខាងក្រោម៖

1 កំណត់ម៉ូដែលព្យាករណ៍ដែលអាចឱ្យផ្ទៀងផ្ទាត់ភាពជាប់ទាក់ទងរវាងការចាកចេញពីប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទៅនឹងតម្រូវការជំនាញនៃទីផ្សារការងារ



2 ដោយសហការជាមួយ NEA និង DLMI ប្រើវិធីសាស្រ្តដែលបានកំណត់ដើម្បីប៉ាន់ប្រមាណការព្យាករណ៍រយៈពេលប្រាំឆ្នាំលើតម្រូវការនិងការផ្គត់ផ្គង់ជំនាញ ប្រសិនបើអាចធ្វើទៅបានដោយ តាមរយៈតំបន់ វិស័យសេដ្ឋកិច្ច`និងមុខរបរ

3 ធ្វើការណែនាំនិងត្រួតពិនិត្យការបណ្តុះបណ្តាលដល់មន្រ្តីរបស់ NEA និង DLMI ក្នុងការរៀបចំនិងអនុវត្តឧបករណ៍ព្យាករណ៍ទីផ្សារការងារនេះ

# ក្របខណ្ឌនៃការវិភាគ

## ដំណាក់កាលនៃជីវិតនិងទីផ្សារការងារ

ភាពតំណាងដ៏សាមញ្ញនៃជីវិតមនុស្សនិងប្រជាជន ធ្លាប់បានបង្ហាញជាគំរូតាមរយៈលំហូរនៃតម្រូវការទីផ្សារការងារ (Bruni, ១៩៨៨, ១៩៩៣)។

បើផ្អែកតាមទស្សនៈសេដ្ឋកិច្ច ដំណាក់កាលនៃជីវិតមនុស្សអាចត្រូវបានបែងចែកជាបីដំណាក់កាលដែលមានលក្ខណៈស្រដៀងគ្នាគឺ ១) ដំណាក់កាលហ្វឹកហាត់និងជីវិតក្នុងដំណាក់កាលហ្វឹកហាត់ ២) ដំណាក់កាលធ្វើការនិងជីវិតគ្រប់អាយុធ្វើការងារ(WAP) ៣)ដំណាក់កាលក្រោយការងារនិងជីវិតក្រោយការងារ។



The flows of the education system

ប្រសិនបើយើងគិតអំពីភាពចន្លោះនៃពេលវេលា មានសញ្ញាព្រួញជាច្រើននៅក្នុងតារាងត្រូវបានផ្តល់ឱ្យជីវិត។ សញ្ញាទាំងនេះបានបង្ហាញឱ្យឃើញអំពីលំហូរអថេរ នៃចំនួនមនុស្សដែលផ្លាស់ប្តូរពីស្ថានភាពមួយទៅស្ថានភាពមួយទៀត(ពីប្រជាជនមួយទៅមនុស្សម្នាក់ទៀត)។ នៅក្នុងចន្លោះនៃភាពប្រែប្រួលនិមួយៗ លំហូររបស់អថេរបានកំណត់នូវបរិមាណនិងគុណភាពនៃការផ្លាស់ប្តូរដែលមាននៅក្នុងអថេរបម្រុងទុក ឬ ស្តុក ៖

ការកើតនិងការស្លាប់បានកំណត់នូវភាពប្រែប្រួលនៃធម្មជាតិរបស់មនុស្ស។ចំនួនមនុស្សដែលមានអាយុ ១៥ ឆ្នាំ ចំនួនមនុស្សដែលមានអាយុ ៦៥ ឆ្នាំនិងការស្លាប់របស់មនុស្សក្នុងវ័យធ្វើការកំណត់ពីភាពប្រែប្រួល នៃធម្មជាតិរបស់មនុស្សក្នុងវ័យធ្វើការ (WAP)។

លំហូរចូលនិងចេញកំណត់នូវកម្រិត រចនាសម្ព័ន្ធនិងនិន្នាការនៃការងារនិងកម្លាំងពលក

ចំនួននៃការកើនឡើងរបស់កម្លាំងពលកម្មក្នុងមួយឆ្នាំៗត្រូវបានកំណត់ដោយប្រព័ន្ធនៃការអប់រំ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ហើយបណ្តុំប្រេកង់ក៏បានបង្ហាញអំពីការចូលទៅក្នុងទីផ្សារការងារក្នុងឆ្នាំនីមួយៗ ដែលជាលទ្ធផលនៃការវិវត្តរបស់អត្រាកំណើត អត្រាប្រជាសាស្ត្រនៃក្រុមយុវជនវ័យក្មេងៗ និងរយៈពេលជាមធ្យមនៃការអប់រំនិងការ បណ្តុះបណ្តាលវិជ្ជាជីវៈរបស់ក្រុមទាំងនោះ។

តាមទស្សនៈទីផ្សារការងារ ជីវិតការងារ (WAP) រួមបញ្ចូលនូវផ្នែកផ្សេងៗទៀតជាច្រើនដែលពាក់ព័ន្ធជាមួយការវិភាគទីផ្សារការងារដូចជា កម្លាំងពលកម្ម (ដែលរួមបញ្ចូលទាំងភាពមានការងារធ្វើ ភាពគ្មានការងារធ្វើនិងការស្វែងរកការងារដំបូង) និងកម្លាំងដែលមិនមែនជាពលកម្ម។ ប្រជាជនទាំងនេះគឺជាកត្តាដ៏សំខាន់សម្រាប់គំរូនេះ។



# របកគំហើញសំខាន់ៗ



**ការរីកចំរើននៃសេដ្ឋកិច្ច-** ក្នុងរយៈពេលជាងបីទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានសម្រេចនូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមគួរឱ្យកត់សម្គាល់។ កំណើនសេដ្ឋកិច្ច ដែលបណ្តាលមកពីវាយនភ័ណ្ឌ ទេសចរណ៍ សំណង់ និងវិស័យកសិកម្មថ្មីៗ បានធ្វើឱ្យមានការចាប់អារម្មណ៍។ បើទោះបីជាកំណើននេះមានការធ្លាក់ចុះបន្ទាប់ពីវិបត្តិសេដ្ឋកិច្ចក៏ដោយ ក៏ប៉ុន្តែចាប់តាំងពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៧ ផលិតផលក្នុងស្រុកសរុប ពិតប្រាកដបានកើនឡើង ២៥០% ហើយផលិតផលក្នុងស្រុកសរុប សម្រាប់មនុស្សម្នាក់ៗ (ដែលគិតត្រឹមពេលនេះមានជិត ១.៥០០ ដុល្លារ) បានកើនឡើងទ្វេដងបើប្រៀបធៀបទៅនឹងស្ថានភាពជាក់ស្តែង។

**ផ្នែកសេដ្ឋកិច្ចនិងសាខាផ្សេងៗទៀត-** ផ្នែកសេដ្ឋកិច្ចសំខាន់ៗ និងសា ខាផ្សេងៗទៀត បានចុះបញ្ជីអត្រាកំណើនខុសគ្នា ដែលបានជះឥទ្ធិពលទៅលើកំណើនផលិតកម្មសរុប និងតួនាទីក្នុងកំណើនសេដ្ឋកិច្ច។ បន្ទាប់ពីវិបត្តិឆ្នាំ ២០០៩ ផលិតផលក្នុងស្រុកសរុបបានកើនឡើងក្នុងអត្រាជាមធ្យម៧% ក្នុងរយៈពេលដូចគ្នាអត្រាកំណើន នៃវិស័យកសិកម្មបានធ្លាក់ចុះមកនៅត្រឹម ២,១% សេវាកម្មបានធ្លាក់ចុះ ៥,៣% ខណៈដែលអត្រានៃកំណើនផ្នែកឧស្សាហកម្មកើនដល់ ១១,២% ។ ជាលទ្ធផល ក្នុងពេលបច្ចុប្បន្ននេះ ចំណែកនៃសេវាកម្មក្នុងតម្លៃបន្ថែមសរុបគឺ ៤២,២% ឧស្សាហកម្ម ៣២,៩% ខណៈពេលដែលវិស័យកសិកម្មធ្លាក់ចុះដល់៤,៩%។

ដើម្បីធ្វើឱ្យកាន់តែមានភាពប្រសើរឡើង ចំពោះស្ថានភាពថ្មីៗនេះ យើងសូមគូសបញ្ជាក់អំពីផ្នែកបីដែលធ្វើឱ្យសេដ្ឋកិច្ចមានការកើនឡើងពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៧ គឺវាយនភ័ណ្ឌ (៣១%) សំណង់ (១១%) និងពាណិជ្ជកម្ម (៩%) ។ ផ្ទុយទៅវិញ ការចូលរួមចំណែករបស់វិស័យកសិកម្មមានតែ ៧,៣% ប៉ុណ្ណោះ (វាមានចំនួន ២១% នៅទសវត្សមុនៗ) ហើយសណ្ឋាគារ និងភោជនីយដ្ឋានបានធ្លាក់ចុះពី ៦,៤% មកនៅត្រឹម ៥,៤% ។

**និន្នាការប្រជាសាស្ត្រ-** ប្រជាជនសរុបមានចំនួន ៤,៤ លាននាក់ក្នុងឆ្នាំ ១៩៥០ បច្ចុប្បន្នមានចំនួន ១៥,៥ លាននាក់ក្នុងឆ្នាំ២០១៥។ ទោះបីជាយ៉ាងណាក៏ដោយ អត្រានៃកំណើននេះមានការថយចុះគួរឱ្យកត់សម្គាល់។ អត្រាសរុបនៃការមានកូននៅតែមានកម្រិតខ្ពស់ ជាងកម្រិតនៃការជំនួស (កុមារ ២,៧ នាក់) ប៉ុន្តែចំនួនកំណើតត្រូវបានគេព្យាករណ៍ថា និងធ្លាក់ចុះពីកម្រិតបច្ចុប្បន្ន៣៦៦,០០០ ទៅ ៣១៨,០០០ នៅពាក់កណ្តាលនៃសតវត្សរ៍នេះ។ ចំណែកប្រជាជនដែលមានអាយុធ្វើការបានឈានដល់ ៦៤,៣% ដូច្នេះនៅប៉ុន្មានឆ្នាំក្រោយប្រទេសកម្ពុជាអាចទទួលបានផលចំណេញពីភាគលាភនៃប្រជាសាស្ត្រ។

**ចំនួនប្រជាជនកម្ពុជារាប់ពាន់នាក់**




ប្រភព: UN DESA data, UN DESA 2019

**ប្រព័ន្ធអប់រំ-** បន្ទាប់ពីឆ្នាំ១៩៨០ ប្រទេសកម្ពុជាបានបោះជំហានយ៉ាងធំ ក្នុងការកសាងប្រព័ន្ធអប់រំជាតិឡើងវិញ។ ការកើនឡើងដ៏ច្រើននៃចំនួនសិស្សត្រូវបានស្របគ្នាជាមួយនឹងការកើនឡើងនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងបុគ្គលិក។ ទិន្នន័យបានបង្ហាញថានៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធអប់រំបាន

ចាប់ផ្តើមប្រឈមមុខ នឹងបញ្ហាពាក់ព័ន្ធនានា ដែលជះឥទ្ធិពលដល់ភាពទៀងទាត់នៃដំណើរការអប់រំ ដូចជាចំនួនលើសលុបនៃកុមារដែលមានអាយុច្រើន ចំនួននៃការបោះបង់ចោលការសិក្សា ភាគច្រើននៅក្នុងកម្រិតបឋម និងមានអត្រាខ្ពស់ការត្រួតថ្នាក់។ ទោះបីជាមានភាពប្រសើរឡើងនៃការចុះឈ្មោះចូលរៀននៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះក៏ដោយ តែនៅក្នុងឆ្នាំសិក្សា ២០១៦-១៧ សិស្សម្នាក់ក្នុងចំណោម ៧ នាក់នៅតែមានអាយុច្រើនដដែលអត្រាត្រួតថ្នាក់នៅបឋមសិក្សាមានចំនួន ៦.៥% ហើយចំនួនច្រើនជាងបីភាគបួនបានដែលបានចាកចេញពីប្រព័ន្ធអប់រំ គឺដោយសារតែការបោះបង់ការសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនភាគរយនៃការបោះបង់ការសិក្សាបានកើនឡើងតាមលំដាប់ជាមួយនឹងកម្រិតអប់រំ។

ការប៉ាន់ប្រមាណដ៏បានបង្ហាញថា ការចាកចេញពី ដំណាក់កាលនៃការបណ្តុះបណ្តាលនាពេលបច្ចុប្បន្នមានប្រហែល ៣១៥,០០០នាក់ ដែលអាចផ្គត់ផ្គង់កម្លាំងពលកម្មលើសពី ២៨០,០០០នាក់ ហើយនៅក្នុងនោះ ៦០%មានការអប់រំតិចជាងថ្នាក់មូលដ្ឋាន (Compulsory) ១៧%មានការអប់រំកម្រិតអនុវិទ្យាល័យ ៦%មានការអប់រំកម្រិតវិទ្យាល័យ និង ១៧% មានការអប់រំកម្រិតមហាវិទ្យាល័យ។

## ការចុះឈ្មោះសរុបតាមភេទនិងតាមកម្រិតថ្នាក់ ជាតម្លៃដាច់ខាត ២០០៥-០៦ ដល់ ២០១៧-១៨

| | 2005-06 | 2006-07 | 2007-08 | 2008-09 | 2009-10 | 2010-11 | 2011-12 | 2012-13 | 2013-14 | 2014-15 | 2015-16 | 2016-17 | 2017-18 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | **Males** | | | | | | | | | | | | |
| grade 1 | 297,736 | 297,032 | 262,977 | 266,599 | 253,277 | 239,901 | 226,136 | 219,638 | 219,230 | 219,564 | 223,186 | 213,579 | 207,318 |
| grade 2 | 250,603 | 243,037 | 236,103 | 222,264 | 226,911 | 219,505 | 208,538 | 197,561 | 193,569 | 194,052 | 197,579 | 200,815 | 195,426 |
| grade 3 | 228,005 | 218,585 | 211,142 | 210,099 | 200,384 | 202,725 | 197,021 | 191,878 | 183,603 | 174,735 | 178,576 | 185,340 | 188,717 |
| grade 4 | 208,812 | 196,230 | 187,839 | 184,453 | 186,673 | 179,690 | 183,515 | 196,174 | 174,479 | 162,096 | 157,799 | 165,818 | 172,452 |
| grade 5 | 194,127 | 178,951 | 167,392 | 163,448 | 162,390 | 164,939 | 160,341 | 193,982 | 161,709 | 152,043 | 146,224 | 146,596 | 153,558 |
| grade 6 | 169,902 | 165,596 | 151,077 | 142,678 | 140,923 | 141,050 | 145,322 | 151,168 | 146,232 | 138,686 | 135,497 | 135,682 | 135,660 |
| grade 7 | 142,807 | 140,732 | 134,919 | 121,714 | 116,109 | 113,770 | 112,020 | 114,200 | 111,401 | 113,897 | 113,535 | 116,259 | 117,915 |
| grade 8 | 103,474 | 111,801 | 111,006 | 104,868 | 96,719 | 92,026 | 88,567 | 85,608 | 88,866 | 84,993 | 88,173 | 89,881 | 93,146 |
| grade 9 | 77,923 | 87,773 | 94,797 | 92,020 | 92,760 | 84,614 | 76,967 | 71,533 | 70,586 | 72,651 | 71,357 | 76,248 | 79,373 |
| grade 10 | 53,321 | 52,835 | 63,797 | 68,491 | 67,359 | 67,124 | 59,714 | 52,976 | 49,907 | 49,677 | 51,696 | 51,785 | 57,431 |
| grade 11 | 34,977 | 44,654 | 45,018 | 53,444 | 60,010 | 58,184 | 55,704 | 48,607 | 43,562 | 40,805 | 40,881 | 43,883 | 44,374 |
| grade 12 | 37,064 | 36,081 | 45,368 | 47,154 | 55,331 | 58,954 | 57,230 | 52,598 | 45,787 | 43,097 | 40,293 | 40,290 | 42,939 |
| Total | **1,798,751** | **1,773,307** | **1,711,435** | **1,677,232** | **1,658,846** | **1,622,482** | **1,571,075** | **1,575,923** | **1,488,931** | **1,446,296** | **1,444,796** | **1,466,176** | **1,488,309** |
| | **Females** | | | | | | | | | | | | |
| grade 1 | 262,435 | 261,231 | 233,471 | 237,406 | 236,725 | 214,435 | 201,301 | 197,019 | 195,721 | 195,999 | 196,245 | 183,642 | 179,546 |
| grade 2 | 217,934 | 212,589 | 208,658 | 196,266 | 200,859 | 195,422 | 186,679 | 179,399 | 174,526 | 175,915 | 179,013 | 180,478 | 171,236 |
| grade 3 | 198,726 | 191,738 | 186,843 | 186,911 | 178,407 | 182,229 | 177,816 | 175,921 | 167,233 | 160,811 | 166,175 | 170,919 | 172,793 |
| grade 4 | 187,369 | 174,828 | 169,260 | 167,060 | 169,985 | 163,205 | 168,272 | 167,243 | 162,158 | 153,042 | 150,754 | 158,118 | 163,096 |
| grade 5 | 181,919 | 164,776 | 153,790 | 151,174 | 150,351 | 153,888 | 148,925 | 168,406 | 153,482 | 147,116 | 143,140 | 144,371 | 151,635 |
| grade 6 | 160,899 | 156,542 | 142,555 | 134,475 | 133,766 | 134,203 | 138,598 | 134,995 | 141,869 | 138,116 | 136,485 | 136,703 | 137,257 |
| grade 7 | 125,280 | 127,388 | 124,561 | 113,086 | 109,924 | 109,720 | 109,146 | 112,317 | 110,589 | 116,131 | 118,974 | 122,633 | 123,069 |
| grade 8 | 82,749 | 94,206 | 98,088 | 96,108 | 89,499 | 87,024 | 85,308 | 84,477 | 89,274 | 87,234 | 94,454 | 99,867 | 104,171 |
| grade 9 | 56,100 | 64,105 | 74,258 | 77,911 | 80,104 | 73,714 | 69,139 | 66,575 | 67,910 | 71,772 | 71,971 | 81,154 | 87,423 |
| grade 10 | 36,062 | 37,480 | 45,832 | 53,146 | 57,248 | 57,696 | 52,367 | 48,560 | 47,826 | 49,799 | 53,827 | 56,253 | 64,802 |
| grade 11 | 22,559 | 29,620 | 31,633 | 38,824 | 46,213 | 49,064 | 47,490 | 42,772 | 40,026 | 39,958 | 41,634 | 46,421 | 48,678 |
| grade 12 | 20,942 | 21,601 | 29,317 | 31,364 | 37,422 | 43,712 | 45,660 | 43,276 | 39,185 | 38,922 | 38,275 | 40,777 | 45,745 |
| Total | **1,552,974** | **1,536,104** | **1,498,266** | **1,483,731** | **1,490,503** | **1,464,312** | **1,430,701** | **1,420,960** | **1,389,799** | **1,374,815** | **1,390,947** | **1,421,336** | **1,449,451** |
| | **Total** | | | | | | | | | | | | |
| grade 1 | 560,171 | 558,263 | 496,448 | 504,005 | 490,002 | 454,336 | 427,437 | 416,657 | 414,951 | 415,563 | 419,431 | 397,221 | 386,864 |
| grade 2 | 468,537 | 455,626 | 444,761 | 418,530 | 427,770 | 414,927 | 395,217 | 376,960 | 368,095 | 369,967 | 376,592 | 381,293 | 366,662 |
| grade 3 | 426,731 | 410,323 | 397,985 | 397,010 | 378,791 | 384,954 | 374,837 | 367,799 | 350,836 | 335,546 | 344,751 | 356,259 | 361,510 |
| grade 4 | 396,181 | 371,058 | 357,099 | 351,513 | 356,658 | 342,895 | 351,787 | 363,417 | 336,637 | 315,138 | 308,553 | 323,936 | 335,548 |
| grade 5 | 376,046 | 343,727 | 321,182 | 314,622 | 312,741 | 318,827 | 309,266 | 362,388 | 315,191 | 299,159 | 289,364 | 290,967 | 305,193 |
| grade 6 | 330,801 | 322,138 | 293,632 | 277,153 | 274,689 | 275,253 | 283,920 | 286,163 | 288,101 | 276,802 | 271,982 | 272,385 | 272,917 |
| grade 7 | 268,087 | 268,120 | 259,480 | 234,800 | 226,033 | 223,490 | 221,166 | 226,517 | 221,990 | 230,028 | 232,509 | 238,892 | 240,984 |
| grade 8 | 186,223 | 206,007 | 209,094 | 200,976 | 186,218 | 179,050 | 173,875 | 170,085 | 178,140 | 172,227 | 182,627 | 189,748 | 197,317 |
| grade 9 | 134,023 | 151,878 | 169,055 | 169,931 | 172,864 | 158,328 | 146,106 | 138,108 | 138,496 | 144,423 | 143,328 | 157,402 | 166,796 |
| grade 10 | 89,383 | 90,315 | 109,629 | 121,637 | 124,607 | 124,820 | 112,081 | 101,536 | 97,733 | 99,476 | 105,523 | 108,038 | 122,233 |
| grade 11 | 57,536 | 74,274 | 76,651 | 92,268 | 106,223 | 107,248 | 103,194 | 91,379 | 83,588 | 80,763 | 82,515 | 90,304 | 93,052 |
| grade 12 | 58,006 | 57,682 | 74,685 | 78,518 | 92,753 | 102,666 | 102,890 | 95,874 | 84,972 | 82,019 | 78,568 | 81,067 | 88,684 |
| Total | **3,351,725** | **3,309,411** | **3,209,701** | **3,160,963** | **3,149,349** | **3,086,794** | **3,001,776** | **2,996,883** | **2,878,730** | **2,821,111** | **2,835,743** | **2,887,512** | **2,937,760** |

Source: The Education Statistics and Indicators, EMIS, Ministry of Education, Youth and Sport

**ទីផ្សារការងារ-** បើផ្អែកតាមស្ថានភាពដែលប្រឈម ទិន្នន័យទីផ្សារការងារ ហើយជាពិសេសភាពអត់ការងារធ្វើ បានបង្ហាញថាវាមានការជាប់ទាក់ទងគ្នាស្ទើរតែមិនអាចខ្វះបានរវាង ការផ្គត់ផ្គង់កម្លាំងពលកម្មនិងតម្រូវការការងារ។ ទោះយ៉ាងណាការសន្និដ្ឋានបែបនេះមិនត្រឹមត្រូវទាំងស្រុងនោះទេ នៅក្នុងស្ថានភាពដែលចំនួនបីភាគបួន នៃកម្លាំងពលកម្មរស់នៅក្នុងតំបន់ជនបទ ហើយការស្រង់ស្ថិតិមានភាពពិបាក ហេតុនេះការវាស់ស្ទង់ភាពអត់ការងារធ្វើ ឬដើម្បីបែងចែកភាពខុសគ្នារវាងភាពមានការងារ និងភាពអត់ការងារធ្វើ ដែលលាក់កំបាំងមិនអាចធ្វើទៅបានទេ ខណៈដែលតំបន់ ទីប្រជុំជនត្រូវបានកំណត់ថាភាពអត់ការងារធ្វើមានចំនួនច្រើន។

ទោះយ៉ាងណា ទិន្នន័យទីផ្សារការងារក៏បានបង្ហាញផងដែរអំពីការផ្លាស់ប្តូរជាច្រើន និងការកែលម្អគុណភាព នៃស្ថានភាពការងារ។ នៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ កម្រិតការងារបានកើនឡើងក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ១៩៣.០០០ ការងារ កសិកម្មបានចាប់ផ្តើមធ្លាក់ចុះក្នុងឆ្នាំ ២០១២ ហើយរហូតមកដល់បច្ចុប្បន្ន ផ្នែកនេះបានធ្លាក់ចុះដល់ ៣៧% ។ ក្នុងរយៈពេលដូចគ្នា កំណើនការងារឧស្សាហកម្ម និងសេវាកម្មបានកើនឡើងជាបន្តបន្ទាប់ដល់ ១៦១,០០០ការងារ និង ១៧៨,០០០ ការងារ ហើយវិស័យទាំងពីរនេះបានរួមចំណែកធ្វើឱ្យការកើនឡើង នៃអត្រាការងារដល់ ២៦,២% និង ៣៦,៨% ។

ទន្ទឹមគ្នានេះ ការបង្ហាញអំពីការកែលម្អគុណភាពការងារបានកើនឡើងគួរឱ្យកត់សម្គាល់ផង ដែរ ជាពិសេស៖

• ភាគរយនៃនិយោជិក ដែលទទួលបានការ តំឡើងប្រាក់ខែពី ២៦% ទៅ ៥១% ខណៈអត្រានៃសមាជិកក្រុមគ្រួសារដែលមិនទទួលបានប្រាក់ឈ្នួលបានធ្លាក់ចុះពី ៣៦% ទៅ ៤%។

• ភាគរយនៃកម្មករជំនាញ ផ្នែកកសិកម្មបានថយចុះមកនៅត្រឹម ៣១% ខណៈដែលផ្នែកសិប្បកម្មបានកើនឡើងពី ១០% ទៅ ២៤% ហើយចំនួនអ្នកលក់ និងកម្មករបំរើសេវាកម្មបានកើនពី ១២% ទៅ ១៨% ។ លើសពីនេះទៅទៀតក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ការរីកចម្រើននៃសិប្បកម្ម និងមុខរបរដែលពាក់ព័ន្ធ ការផ្តល់សេវាកម្មនិងអ្នកលក់ និងការងារការិយាល័យ មានការកើនឡើងដោយឡែកពីគ្នាគឺ ៥៤%, ១៨% និង ១៣% នៃកំណើនការងារសរុប ខណៈដែលផ្នែកពាក់ព័ន្ធផ្សេងៗទៀតដូចជាការដាំដុះ អ្នកបើកបរគ្រឿងយន្ត អ្នកជំនាញនិងអ្នកបច្ចេកទេសបានរួមចំណែកផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ចំនួនអ្នកគ្រប់គ្រង អ្នកជំនាញនិងអ្នកបច្ចេកទេស បានធ្លាក់ចុះបន្តិចត្រឹមតែ ៦% ខណៈដែលកម្មករមិនមានជំនាញមានអត្រាលើសពី ១០% ។

• កម្រិតនៃការអប់រំរបស់កំលាំងពលកម្ម មានភាពល្អប្រសើរ ប៉ុន្តែនៅតែទាបដដែលគឺ ៧០% មិនបានបញ្ចប់ការអប់រំថ្នាក់មូលដ្ឋាន តិចជាងអនុវិទ្យាល័យ (compulsory) ហើយអ្នកដែលមានការអប់រំខ្ពស់គឺ ៨% និង ៧% មានសញ្ញាប័ត្រក្រោយមធ្យមសិក្សា។ ទោះយ៉ាងណា វាជាកត្តាវិជ្ជមានមួយដែលក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ៣៤%នៃការងារបន្ថែមបានទទួលយកមនុស្ស ដែលមានការអប់រំកម្រិតក្រោយមធ្យមសិក្សា ហើយក្នុងរយៈពេលដូចគ្នានេះ ក៏មានការកើនឡើងចំនួន នៃការងារសម្រាប់អ្នកដែលមានការអប់រំទាបជាងកម្រិតបឋម ឬបឋមផងដែរ។

## សេណារីយ៉ូ

សេណារីយ៉ូត្រូវបានគេប៉ាន់ស្មាន តាមរយៈគំរូលំហូរស្តុកនៃទីផ្សារការងារ ដែលអាចវាយតម្លៃបានថាតើមានមនុស្សប៉ុន្មាននាក់ សម្រាប់តម្រូវការទីផ្សារ និងចំនួនប៉ុន្មាននាក់ ដែលនឹងត្រូវចាត់ចូលក្នុងកម្លាំងពលកម្ម ដើម្បីវិភាគអំពីភាពជាប់ទាក់ទងនៃបរិមាណនិងគុណភាពរបស់លំហូរទាំងពីរនេះ។

**ការវិភាគលំហូរស្តុក នៃទីផ្សារការងារកម្ពុជាសម្រាប់ឆ្នាំ ២០០៧-២០១៧** - ការវិភាគបង្ហាញថាក្នុងចន្លោះឆ្នាំ ២០០៧ និង ២០១៧៖

- ជាមធ្យមរៀងរាល់ឆ្នាំ យុវជនកម្ពុជា ២៦១.០០០នាក់ បានរកការងារធ្វើជាលើកដំបូង។
- ការបង្កើតការងារបន្ថែម បានរួមចំណែក ៧៩% ហើយបំពេញបន្ថែមអនកជំនាន់ថ្មី ២១%
- ៩២% នៃអ្នកចូលរួមស្ថិតនៅក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ និង ៨% ទៀតនៅក្នុងក្រុមអាយុ ២០-២៤ឆ្នាំ
- ២/៣ នៃអ្នកដែលចាកចេញឈប់ធ្វើការងារស្ថិតនៅក្នុងក្រុមអាយុ ៥៥-៦៤ និង ២៦% នៅក្នុងក្រុមអាយុចន្លោះនេះ។
- ការកែលម្អកម្រិតអប់រំ ដែលយើងបានសង្កេតរួចហើយ មានភាពខុសគ្នារវាងកម្រិត នៃការអប់រំរបស់អ្នកដែលចូលធ្វើការនិងអ្នកដែលឈប់ពីការងារ។

## សេណារីយ៉ូឆ្នាំ ២០១៧-២០២៧

**ផ្នែកតម្រូវការ** - អាយុជាមធ្យមខ្ពស់នៃអ្នកមានការងារធ្វើត្រូវបានប៉ាន់ស្មានថាចាប់ពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០២៧ ការឈប់ធ្វើការងារនឹងមានច្រើនជាងកាលពីមុនគឺ ១,០៤៥ លាន។

ចំនួនការងារ ដែលត្រូវបានបង្កើតឡើងតាមរយៈសេដ្ឋកិច្ចកម្ពុជា (តម្រូវការបន្ថែម) នឹងត្រូវបានកំណត់ដោយអត្រាកំណើនផលិតកម្ម និងផលិតភាព ហើយដំណើរការពីពេលមុន នឹងត្រូវពឹងផ្អែកយ៉ាងខ្លាំងលើបរិមាណ និងប្រភេទនៃការវិនិយោគដោយផ្ទាល់ក្នុងស្រុក និងពាណិជ្ជកម្មអន្តរជាតិ បន្ទាប់មកទៀតគឺត្រូវពឹងផ្អែកលើបច្ចេកវិទ្យា ដែលល្អប្រសើរជាងមុន កម្មករដែលមានការអប់រំច្រើន និងការបណ្តុះបណ្តាលដែលប្រសើរ ការធ្វើឱ្យមានភាពប្រសើរឡើងនៃស្ថាប័នការងា និងការឆ្លងកាត់រចនាសម្ព័ន្ធផលិតកម្មដែលប្រកបដោយបច្ចេកវិទ្យាខ្ពស់។

និន្នាការនាពេលកន្លងមក និងសុចនាករ នាពេលថ្មីៗរបស់ស្ថាប័នសាធារណៈ នៅកម្ពុជាបានស្នើឱ្យមានការអនុម័តអត្រាមធ្យមចំនួនបី នៃកំណើនផលិតផលក្នុងស្រុក (៦% ៧% និង ៨%) និងបង្កើតបានជា មេគុណកំណើន (Elasticity) ប្រាក់ចំណូលការងារចំនួនបី (០,២០%, ០,២៥% និង ០,៣០%)។ បន្ទាប់មកទៀត នៅក្នុងតម្លៃនៃអតីតកាល បានបង្ហាញថាភាពចាស់ទុំ និងការទាក់ទាញពីការងារសំណង់និងផលិតកម្មអាច ពន្លឿនការចាកចេញពីតំបន់ជនបទនិងមុខរបរកសិកម្ម ខណៈដែលការច្នៃប្រឌិត ផ្នែកបច្ចេកវិទ្យាចាំបាច់ត្រូវបានណែនាំនៅក្នុងគ្រប់វិស័យ ដើម្បីជំរុញឱ្យមានការប្រកួតប្រជែងនៃប្រព័ន្ធផលិតកម្មកម្ពុជា។

អត្រាកំណើនការងារទាំង៩កម្រិត ត្រូវបានរាប់បញ្ចូលរវាងអប្បបរមា ១,២% និងអតិបរិមា ២,៤% និង ១,៧៥% នៅក្នុងសេណារីយ៉ូកម្រិតមធ្យមដែលឆ្លើយតបទៅនឹងការកើនឡើងជាមធ្យមនៃការងារស្មើនឹង១១១,០០០ការងារ ២៣៥,០០០ការងារ និង ១៦៦,០០០ការងារ តាមលំដាប់លំដោយ។ ការប្រៀបធៀបជាមួយនឹងកំណើនដែលរំពឹងទុក នៃចំនួនប្រជាជន ដែលគ្រប់អាយុធ្វើការបានផ្តល់នូវលទ្ធផលសំខាន់ទីមួយ៖ អត្រានៃការរីកចម្រើនរបស់ GPD

លើសពី ៧% នឹងតម្រូវឱ្យមានការប្រែប្រួលនូវ មេគុណកំណើន (Elasticity) ប្រាក់ចំណូលការងារទាបជាង ០,២៥ ហេតុនេះអត្រាខ្ពស់នៃការផ្លាស់ប្តូរបច្ចេកវិទ្យានិងកើតមាន។

ដោយផ្តោតលើការវិភាគលើសេណារីយ៉ូកម្រិតមធ្យម របាយការណ៍នេះបានបង្ហាញថាការងារកសិកម្មត្រូវបានគេរំពឹងថា នឹងធ្លាក់ចុះក្នុងអត្រាប្រចាំឆ្នាំប្រចាំឆ្នាំ ១៧៨.០០០ ខណៈពេលដែលការងារឧស្សាហកម្មនឹងកើនឡើង ១៨៣.០០០ និងសេវាកម្ម ១៧៨.០០០ ។ កត្តានេះធ្វើឱ្យមានការកត់សម្គាល់នៃភាពផ្លាស់ប្តូររចនាសម្ព័ន្ធការងារតាម វិស័យដោយវិស័យកសិកម្មធ្លាក់ចុះដល់ ១៤% ឧស្សាហកម្មកើនឡើងដល់ ៣៩,៦% និងសេវាកម្មដល់ ៤៦,៤% ។ ភាពអវិជ្ជមានបន្ថែមនៃតម្រូវការកសិកម្មមិនបញ្ជាក់ថាកសិកម្មនឹងមិនត្រូវបានរាប់បញ្ចូលនោះទេ។ តាមពិតវាបានបង្ហាញពីការចាកចេញយ៉ាងច្បាស់លាស់ របស់មនុស្សវ័យចំណាស់និងការផ្លាស់មកវិញនូវកម្មករវ័យក្មេង ទៅឧស្សាហកម្ម និងសេវាកម្ម ដែលភាគច្រើនសម្រាប់វិស័យ សំណង់ វិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដែលនឹងបន្តស្រូបយកកម្មករ ដែលមានការអប់រំកម្រិតទាប) ដែលធ្វើឱ្យមានតុល្យភាពដោយផ្អែកលើការបញ្ចូលកូនចៅរបស់កសិករសព្វថ្ងៃ។

ការរួមផ្សំនៃតម្រូវការបន្ថែម នៅក្នុងសេណារីយ៉ូកម្រិតមធ្យម និងតម្រូវការនៃការផ្លាស់ប្តូរ បានប៉ាន់ប្រមាណថា តម្រូវការការងារអាចស្រូបយកយុវជនប្រហែល ២៧០,០០០នាក់ក្នុងមួយឆ្នាំ។ បើផ្អែកលើនិន្នាការនាពេលកន្លងមក របាយការណ៍នេះបានបង្ហាញថា ៣៤% នៃកំលាំងពលកម្មនៅតែមានការអប់រំទាបជាងកម្រិតបឋម ២៣% មានការអប់រំនូវកម្រិតមធ្យមសិក្សា និង២៣% មានកម្រិតអប់រំថ្នាក់វិទ្យាល័យ។ កម្រិតអប់រំជាមធ្យមសម្រាប់អ្នកដែលឈប់ពីការងារធ្វើនៅតែទាប ដែលគួរឱ្យកត់សម្គាល់ដូច្នេះកម្រិត នៃការអប់រំរបស់អ្នកមានការងារនឹងកើនឡើង ប៉ុន្តែការកើនឡើងនេះមិនគួរឱ្យកត់សម្គាល់នោះទេ។ នៅឆ្នាំ ២០២៧ ចំនួនប្រជាជនដែល មានការអប់រំតិចជាងកម្រិតបឋមសិក្សា នៅតែមានអត្រាខ្ពស់រហូតដល់ ៥៩% ប៉ុន្តែចំនួននៃអ្នកដែលមានការងារធ្វើ ហើយមានការអប់រំយ៉ាងហោចណាស់នៅមធ្យមសិក្សា ត្រូវគេរំពឹងថានឹងកើនឡើងពី ៨,២% ទៅ ១២,៤% ។

**ផ្នែកផ្គត់ផ្គង់** - ការផ្គត់ផ្គង់កម្លាំងពលកម្មដែលមានលក្ខណៈជាលំហូរត្រូវតែ ផ្តល់ដោយចំនួនមនុស្សដែលគ្រប់អាយុធ្វើការ ក្នុងចន្លោះពេលណាមួយ។ យោងតាមការព្យាករ នូវចំនួនប្រជាជនរបស់UN DESA (UN DESA ២០១៩) នៅចន្លោះឆ្នាំ ២០១៧ និង ២០២៧ ចំនួនមនុស្សដែលគ្រប់អាយុធ្វើការនឹងមានចំនួន ៣,២ លាននាក់។ របាយការណ៍សន្និដ្ឋានថាចំនួនមនុស្ស ដែលគ្រប់អាយុធ្វើការ និងនៅថេដែលប៉ាន់ស្មានហក់ចូលក្នុងកម្លាំងពលកម្ម ២,៦៣៤ លាននាក់។

ដើម្បីញែកនូវចំនួនមនុស្ស ដែលគ្រប់អាយុធ្វើការតាមកម្រិតនៃការអប់រំ របាយការណ៍បានបង្ហាញពីការព្យាករណ៍ពីរដែលកើតចេញពីប្រព័ន្ធអប់រំ និងផ្នែកអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ(អ.ប.វ.) ដោយផ្អែកលើការសន្និដ្ឋានដំបូងថា អត្រាជាក់លាក់នៃការបន្តរៀនសូត្រ នៅតែជាបញ្ហានៅកម្រិតនៃឆ្នាំសិក្សា ២០១៦-១៧ ហើយការសន្និដ្ឋានទីពីរដែលកាន់តែជាក់ស្តែង ជាងនេះទៀតនោះគឺថាពួកគេនឹងកែលម្អជាបណ្តើរៗ។ ដូចការរំពឹងទុក កម្រិតនៃការចាកចេញពីការអប់រំ មានភាពប្រសើរឡើងនៅក្នុងសេណារីយ៉ូទីពីរជាជាងទីមួយ ខណៈពេលនៅក្នុងឆ្នាំ ២០១៧ សិស្ស ៦០% ដែលបានបោះបង់ការសិក្សាមិនបានបញ្ចប់កម្រិតមូលដ្ឋាន (compulsory) នោះទេ ហើយ ៤០% យ៉ាងហោចណាស់បានទទួលការអប់រំ

នៅកម្រិតមូលដ្ឋាន ការបែងចែកនេះត្រូវបានគេប៉ាន់ប្រមាណថាមាន ៥០% និង ៥០% នៅក្នុងសេណារីយ៉ូទីមួយ ហើយ ៤០% និង ៦០% នៅក្នុងសេណារីយ៉ូទីពីរ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ជានេះទៅទៀតនោះ គឺកម្រិតមហាវិទ្យាល័យដែលបានឈានទៅដល់ ២០% ក្នុងឆ្នាំ ២០១៧។

របាយការណ៍ចុងក្រោយបានបង្ហាញថា ការបោះបង់ពីដំណាក់កាលបណ្តុះបណ្តាល (សេណារីយ៉ូទី២) និងតម្រូវការទីផ្សារការងារ (សេណារីយ៉ូកម្រិតមធ្យម) តាមកម្រិតអប់រំសម្រាប់ឆ្នាំ ២០១៧-២០២៧ មានលក្ខណៈសមហេតុសមផល។ ការប៉ាន់ប្រមាណនេះបានបង្ហាញថា ការបោះបង់ចោលសាលាគឺស្របគ្នានឹងតម្រូវការទីផ្សារការងារ ហើយជាគុណតម្លៃតែមួយគត់ ដែលលើសពីកម្រិតនៃការអប់រំទាបបំផុត ដែលជាទូទៅត្រូវបានកំណត់ដោយទំនោរទាបនៃការក្លាយជាកំលាំងពលកម្ម។

## តម្រូវការជំនាញនិងតម្រូវការបណ្តុះបណ្តាលឆ្នាំ ២០១៧-២០២២

ផ្នែកតម្រូវការ - កំណើនការងារសរុបដែលត្រូវបានប៉ាន់ប្រមាណមានចំនួន ៧៩៥,០០០ នាក់គឺជាលទ្ធផល នៃការធ្លាក់ចុះចំនួនការងារក្នុងវិស័យកសិកម្ម ៨០៨.០០០ នាក់ និងការកើនឡើងក្នុងវិស័យឧស្សាហកម្ម ៨៥០,០០០នាក់ និងសេវាកម្ម ៧៥៣,០០០នាក់។ នៅពេលដែលតម្រូវការជំនួស និងការផ្ទេរពីកសិកម្មទៅវិស័យសំខាន់ពីរផ្សេងទៀត ត្រូវបានគេយកមកពិចារណា នោះការចូលក្នុង ទីផ្សារការងារក្នុងវិស័យកសិកម្មត្រូវបានប៉ាន់ប្រមាណស្មើនឹង ៤០,០០០ នាក់ និងឧស្សាហកម្មរហូតដល់ ១៩៦.០០០ នាក់ (១១៣,០០០ នាក់ចូលដំបូងនិងការផ្ទេរពីកសិកម្ម ៨៣,០០០នាក់) និងក្នុងវិស័យសេវាកម្ម ១៨៨,០០០នាក់ (១០៩.០០០នាក់ចូលដំបូង និងការផ្ទេរពីកសិកម្ម ៧៩.០០០នាក់)។

ការវិភាគតម្រូវការការងារ តាមមុខរបរសំខាន់ៗ អនុញ្ញាតឱ្យបង្ហាញរូបភាពជាមូលដ្ឋាន នៃតម្រូវការជំនាញនិងតម្រូវការបណ្តុះបណ្តាល។ ក្នុងរបាយការណ៍នេះយើងបានប៉ាន់ប្រមាណថា ក្នុងចំណោមមនុស្ស ៤៩០.០០០នាក់ ជាមធ្យមប្រចាំឆ្នាំដែលចូលធ្វើការងារ នៅក្នុងវិស័យធំៗចំនួន៣ ដែលប្រមាណ ៣/៤ នឹងស្ថិតនៅពាក់ព័ន្ធដើរតួយ៉ាងសំខាន់ (៥៧%) បន្ទាប់មកគឺកម្មករសេវាកម្ម និងអ្នកលក់(១៤%) និងកម្មករគាំទ្រស្មៀន(១៣%)។ តួនាទីតូចតាច ប៉ុន្តែមានលក្ខណៈគុណភាព នឹងត្រូវបានបំពេញដោយប្រតិបត្តិកររោងចក្រ និងម៉ាស៊ីន អ្នកជំនាញនិងអ្នកបច្ចេកទេស។

ការប្រើប្រាស់រួមបញ្ចូលគ្នា នៃប្រភពផ្សេងៗគ្នា រួមទាំងសន្ទស្សន៍ការងារ របស់ភ្នាក់ងារមុខរបរជាតិ និងការងារ(NEA) អាចឱ្យយើងផ្តល់នូវការប៉ាន់ស្មានបរិមាណ នៃតម្រូវការទាក់ទងនឹងលំហូរសម្រាប់មុខរបរតែមួយ និងការចង្អុលបង្ហាញពីមុខរបរដែលមានលក្ខណៈដោយកង្វះការផ្គត់ផ្គង់។ ការស្រាវជ្រាវបានចង្អុលបង្ហាញពីតួនាទីសំខាន់ ដែលនឹងត្រូវបានបំពេញដោយមុខរបរតែមួយនៃវិស័យសំណង់ វិស័យកាត់ដេរ កន្លែងស្នាក់នៅនិងភោជនីយដ្ឋាន និងដោយវិស័យពាណិជ្ជកម្មលក់រាយ។

ប៉ុន្តែក៏មានមុខរបរសំខាន់ៗ ដែលទាមទាឱ្យមានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា។ សូចនាករទាំងនេះមានសារៈសំខាន់ សម្រាប់តម្រូវការ អប់រំ និងបណ្តុះបណ្តាលដោយក្រសួងពាក់ព័ន្ធ និងជាពិសេសដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ចំពោះផ្នែកផ្គត់ផ្គង់វិញ ការវិភាគនៃវគ្គបណ្តុះបណ្តាល (អ.ប.វ.) នៅកម្រិតវិញ្ញាបនបត្រ និងកម្រិតសាកលវិទ្យាល័យ បង្ហាញថាចំណែកនៃការផ្គត់ផ្គង់កម្លាំងពលកម្មដែលបានគ្របដណ្តប់ដោយ វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ គឺមាគុណភាពដែលបរិមាណមាន

កំណត់ ដូច្នេះគួរតែពង្រីកការបណ្តុះ បណ្តាលវិជ្ជាជីវៈ
ភ្លាមៗនៅក្នុងទិសដៅចង្អុលបង្ហាញ ក្នុងរបាយការណ៍។




| | Average yearly Labour demand in terms of flow | Occupations for which labour supply is insufficent and training necessary | Occupations for which the supply is in line with demand but training would provide an important plus |
|---|---|---|---|
| **Craft and related workers** | **244,000** | | |
| *Cccupations of the construction sector* | *100,000* | Construction supervisors, Plumbers and Pipe fitters, Glaziers, Welders, Painters, Building construction laborers | Civil engineers, Architects, Civil engineering technicians, Bricklayers, Roofers, Concrete workers, building and related electricians, plasterers. |
| *Occupations of the garment sector* | *80,000* | Manufacturing supervisors, Garment designer, Production clerk; Fur and leather products machine operator; Footwear, textile and related trades workers; Packing and labelling machine operators, Hand packers, Manufacturing laborers | |
| *Other Occupations* | *64,000* | Wood workers; food workers | |
| **Service and sales workers** | **62,000** | | |
| *Tourism* | *32,000* | Chefs, Bartenders, and Hotel and restaurant managers. | Receptionists, Cooks, Kitchen helpers, Waiters, Fast food preparers, Cleaners and helpers |
| *Retail trade* | *30,000* | Shop supervisors, Cashiers, Sales and marketing managers, Sale demonstrators and ICT sale persons | salespersons for shops, stalls, and street-food shops |
| **Clerical support workers** | **56,000** | Administrative and executive secretaries; Office clerks; Bank tellers, Bank clerks, Contact centre information clerks, | |
| **Agriculture, forestry and fishery** | **40,000** | Agricultre engineer, Soil and plant specialist, Agriculture food scientist, Agronomist, Horticulture technician, Hydraiulics technician, Wildlife and forestry management and conservation, Fisheries bilogist, Fisheries manager, | |
| **Plant and machine operators and assemblers** | **27,000** | Industrial and production engineers, Mechanical engineers; Steam engine and boiler operators, Mechanical machinery assemblers, Machinery mechanics and repairers, Heavy truck and lorry drivers. | |
| **Technicians and professionals** | **41,000** | | |
| *Health sector* | | Radiographers, Medical and pathology laboratory technician, Dental assistant, Midwifes | |
| *Tourism* | | Translators and interpreters; Accountants and marketing professionals. | |
| *IT sector* | | ICT user support technicians, System analysts and IT architects, Software and system developers, ICT operations technicians, Database and network professionals, Information technology trainers, Computer network and systems technicians | |

ប្រភព- Authors’ Calculation National Institute of Statistics (2019), CSES

## ការផ្តល់យោបល់គោលនយោបាយ

ការរកឃើញដ៏សំខាន់នៃរបាយការណ៍នេះ គឺថា ទីផ្សារការងារ នៅប្រទេសកម្ពុជាទទួលរងសម្ពាធពីកម្រិតអប់រំទាប នៃកម្លាំងពលកម្ម។ វាជាបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធរចនាសម្ព័ន្ធ ហើយអាចដោះស្រាយបានក្នុងរយៈពេលមធ្យមមួយ តាមរយៈការបង្កើនឱ្យសំរេចបាន នូវការអប់រំសម្រាប់សិស្សដែលបានចាកចេញពីដំណាក់កាលបណ្តុះបណ្តាល។

កម្លាំងពលកម្មដែលមានកម្រិត នៃអប់រំខ្ពស់បំផុត គឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងដំណាក់កាលជាប្រវត្តិសាស្ត្រនេះ មិនមែនដោយសារតម្រូវការដ៏ច្រើន នៃកម្លាំងពលកម្មដែលទទួលបានការអប់រំខ្ពស់នៅតាមផ្នែកជាច្រើន នៃវិស័យសេវាកម្មនោះទេ ប៉ុន្តែដោយសារវាតំណាងឱ្យតម្រូវការជាបឋម មុននឹងទទួលបាននូវជំនាញ និងសមត្ថភាពដែលកំណត់ដោយបច្ចេកវិទ្យាថ្មីៗ ហើយនិងត្រូវបាន ប្រើប្រាស់នៅក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម។ វាត្រូវបានបញ្ជាក់ដោយនិយោជកថា និស្សិតដែលបានបញ្ចប់ការសិក្សាពី TVET មានភាពខ្វះខាតជាច្រើន ដូចជាកង្វះជំនាញមូលដ្ឋាននៅក្នុងការអាន ការសរសេរ និងគណិតវិទ្យាដែលវាមិនមែនជាកំហុសទាំងស្រុង នៃការបណ្តុះបណ្តាលវិជ្ជាជីវៈនោះទេ ប៉ុន្តែវាជាកង្វះខាតនៃការអប់រំ។

ការបង្កើនប្រសិទ្ធភាពការងារ របស់កម្លាំងពលកម្មក៏ត្រូវបានលើកឡើងផងដែរ ពីព្រោះដោយសារការប្រែប្រួលអត្រាប្រជាសាស្ត្រកើនឡើង កម្លាំងពលកម្មអាចថយចុះជាចាំបាច់ ហើយការចំណាកស្រុកទៅប្រទេសជិតខាង អាចធ្វើឱ្យកង្វះខាតកម្លាំងពលកម្មជំនាញក្នុងស្រុកកាន់តែថយចុះថែមទៀត។

## ការកាត់បន្ថយអត្រាបោះបង់នៃការសិក្សា

ភាគច្រើននៃការបោះបង់ចោលការសិក្សា ប្រព្រឹត្តទៅមិនមែននៅចុងបញ្ចប់នៃឆ្នាំសិក្សាទេ ប៉ុន្តែនៅក្នុងដំណាក់កាលនៃឆ្នាំសិក្សា ហើយអ្នកដែលបានបោះបង់នៅកម្រិតបឋមសិក្សាដែលជាពិសេស និងជះឥទ្ធិពលធំធេង។ លទ្ធផលនៃការវិភាគរបស់យើងបានបង្ហាញថា ការកាត់បន្ថយអត្រាបោះបង់ចោលការសិក្សា នឹងជះឥទ្ធិពលភ្លាមៗទៅលើរយៈពេលជាមធ្យមនៃដំណើរការអប់រំ។

មូលហេតុជាច្រើន នៃការបោះបង់ចោលការសិក្សាជាដំបូងអាចងាយយល់។ របាយការណ៍កន្លងទៅរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានលើកឡើងថា "ភាពក្រីក្របានជំរុញកុមារជាច្រើន ឲ្យក្លាយជាកម្លាំងពលកម្ម មុនពេលពួកគេទទួលបានការសិក្សាច្រើន ហើយការកង្វះអាហារូបត្ថម្ភ បានជះឥទ្ធិពលដល់អ្វីដែលពួកគេអាចរៀនបាន នៅពេលពួកគេនៅសាលារៀន" (ADB ឆ្នាំ ២០១៥) ។ ចំពោះបញ្ហាដែលបានលើកឡើងនេះ វាហាក់ដូចជាពាក់ព័ន្ធជាមួយនិងការរៀបចំការស្ទង់មតិមួយ ដែលមានគោលបំណងស៊ើបអង្កេតតាមរបៀបសាមញ្ញអំពីមូលហេតុដើម នៃបញ្ហា និងដើម្បីរៀបចំនូវវិធានការមួយដែលមានប្រសិទ្ធិភាពសម្រាប់ដោះស្រាយបញ្ហានេះ។

## ការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការអប់រំ

ការវិភាគបានបង្ហាញថា នាពេលអនាគតចំនួនសិស្ស ដែលបានចុះឈ្មោះចូលរៀននៅក្នុងប្រព័ន្ធអប់រំនឹងមិនមានការកើនឡើងច្រើននោះទេ ក្នុងដំណាក់កាលនេះ វាហាក់ដូចជាមានលទ្ធភាពនិងសមស្របក្នុងការវិនិយោគ លើគុណភាពនៃការអប់រំ។ យោងតាមការសិក្សា របស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដដែលបានបង្ហាញថា បញ្ហាប្រឈមមួយទៀតគឺគុណភាព និងភាពពាក់ព័ន្ធផ្សេងទៀត សម្រាប់ការអប់រំដែលកំពុងផ្តល់នាពេលបច្ចុប្បន្ន។ មូលហេតុមួយនៃបញ្ហាគុណភាពនៅក្នុងការអប់រំ គឺថាគ្រូខ្លួនឯងច្រើនតែមិនមានគុណភាពគ្រប់គ្រាន់។ ការកែលំអគុណភាពគ្រូនិងសន្ទស្សន៍រវាងសិស្ស និងគ្រូមិនត្រឹមតែ

អាចបង្កើន នូវគុណភាពនាពេលបញ្ចប់ការសិក្សាប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចកាត់បន្ថយអត្រារៀនត្រួតថ្នាក់ទៀតផងដែរ ដែលជាបញ្ហាមួយមានលក្ខណៈជាប្រព័ន្ធ និងប៉ះពាល់ដល់ភាពទៀងទាត់ និងប្រសិទ្ធភាព នៃដំណើរការបណ្តុះបណ្តាល។

**ការកំណត់តួនាទីរបស់ TVET** - របាយការណ៍នេះបានបង្ហាញតិចតួចអំពី TVET ហើយមូលហេតុចំបងគឺចំនួនសិស្ស និងអត្រាបញ្ចប់ការសិក្សាពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានកម្រិតទាប (ប្រហែល ១% នៃចំនួនសរុប) និងកង្វះខាតព័ត៌មានស្ថិតិ។ ទោះយ៉ាងណាក៏ដោយ វាត្រូវបានគេសង្ឃឹមថាតួនាទី និងភាពពាក់ព័ន្ធរបស់ TVET នឹងកើនឡើង។ មានកត្តាបីដែលអាចធ្វើឱ្យតួនាទីរបស់ TVET មានសក្តានុពល។

កត្តាទីមួយៈ TVET គួរតែដើរតួនាទីជាបណ្តាញសុវត្ថិភាពសម្រាប់កុមារា និងកុមារី ដែលបានបោះបង់ចោលការសិក្សានៅកម្រិតមូលដ្ឋាន។ ការធ្វើតួនាទីបែបនេះ TVET អាចចូលរួមជួយកុមារទាំងនោះឱ្យទទួលបាននូវការអប់រំដែលចាំបាច់ ហើយក្នុងពេលជាមួយគ្នានោះក៏អាចផ្តល់ ឱ្យពួកគេនូវសម្ភារៈទៅតាមតម្រូវការទីផ្សារផងដែរ។

កត្តាទីពីរៈ TVET គួរតែពង្រីកសកម្មភាពរបស់ខ្លួនដោយទាក់ទាញកុមារា និងកុមារី ដែលបានបញ្ចប់ការអប់រំនៅកម្រិតមូលដ្ឋាន ឬកម្រិតសិក្សាខ្ពស់ហើយផ្តល់ឱ្យពួកគេនូវជំនាញ និងសមត្ថភាពដែលជាតម្រូវការទីផ្សារ។ វាជាបញ្ហាសារមេញទូទៅដែលការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅប្រទេសកម្ពុជាត្រូវបានប្រឈមមុខ ដូចជានៅប្រទេសជាច្រើនក្នុងពិភពលោកផងដែរ ដោយការយល់ឃើញបែបអវិជ្ជមាន ហើយត្រូវបានគេមើលឃើញថាវាជាដំណោះស្រាយជម្រើសទីពីរ។ ចក្ខុវិស័យនេះច្រើនតែបណ្តាលមកពីកង្វះខាត នៃការទទួលស្គាល់អំពីស្ថានភាពនិងភាពជាប់ទាក់ទង នៃការងារដែល TVET រៀបចំសម្រាប់សិស្ស។ ដើម្បីពង្រីកវិសាលភាពនៃ TVET ឱ្យមានសារៈសំខាន់ វាមិនគ្រាន់តែជាការបង្ហាញពីភាពពាក់ព័ន្ធ និងផ្សព្វផ្សាយពីវត្តមានរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែគឺត្រូវធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសង្គម និងការផ្តល់សេដ្ឋកិច្ចប្រាក់ឈ្នួលសម្រាប់មុខរបរ TVET ផងដែរ។

កត្តាទីបីៈ វាត្រូវបានគេទទួលស្គាល់ជាទូទៅថា នៅពេលខាងមុខការច្នៃប្រឌិត នៃបច្ចេកវិទ្យាដែលមិនធ្លាប់មានពីមុនមក នឹងជះឥទ្ធិពលដល់គ្រប់វិស័យសេដ្ឋកិច្ច។ កត្តានេះនឹងតម្រូវឱ្យមានការឆ្លើយតបមួយចំនួនធំដែលស្ថាប័ន TVET អាចផ្តល់កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន។

កត្តាមួយចំនួនចុងក្រោយគឺ ការធ្វើឱ្យការងារនៅក្នុងវិស័យកសិកម្មមានសារៈសំខាន់ សម្រាប់ការអភិវឌ្ឍប្រទេស។ ការកាត់បន្ថយកំលាំងពលកម្មយ៉ាងច្រើនដែលវិស័យនេះបង្ហាញ ការដើរតួនាទីស្នូល ដែលវិស័យនេះអាចធ្វើឱ្យសេដ្ឋកិច្ចរបស់កម្ពុជា មានការងើបឡើងវិញ ភាពចាំបាច់ក្នុងការបង្កើន ផលិតភាពតាមរយៈ ការទទួលយកនូវបច្ចេកវិទ្យាទំនើបបំផុត បង្ហាញថាស្ថាប័ន TVET គួរតែយកចិត្តទុកដាក់ជាពិសេសទៅលើវិស័យកសិកម្ម។

**គោលនយោបាយ នៃការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧស្សាហកម្ម** - ដើម្បីរៀបចំផែនការ និងប្រព័ន្ធ នៃការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្វីដែលយើងត្រូវការ គឺជាការព្យាករណ៍នៃតម្រូវការការងារដែលមានលក្ខណៈសាមញ្ញ។ ជាដំបូងអ្នកសេដ្ឋកិច្ចមិនមែនជាគ្រូទាយទេ ហើយអ្វីដែលពួកគេអាចធ្វើបាន គួរតែធ្វើដើម្បីផ្តល់នូវចក្ខុវិស័យថ្មីមួយ សម្រាប់អនាគតដោយផ្អែកលើគុណតម្លៃខុសគ្នានៃបញ្ហាអថេរមូលដ្ឋាន។ សេណារីយ៉ូទាំងនេះ នឹងប្រាប់អ្នកធ្វើគោលនយោបាយពីអ្វី ដែលនឹងកើតឡើង ប្រសិនបើព្រឹត្តិការណ៍ជាក់លាក់ ហើយនឹងកើតឡើងហើយ

ឬគោលនយោបាយជាក់លាក់ នឹងត្រូវបានអនុម័ត។ សេណារីយ៉ូនេះ គឺជាឧបករណ៍ដែលជួយអ្នកធ្វើគោលនយោបាយឱ្យធ្វើការសម្រេចចិត្តផ្អែកលើភស្តុតាង។ ចំនុចទីពីរគឺ អនាគតជាការបង្កើតដោយផ្ទាល់របស់ពួកយើង។ នេះបញ្ជាក់ថាការបណ្តុះបណ្តាលដែលត្រូវការជាចាំបាច់ភាគច្រើនពឹងផ្អែកលើចំនួន និងប្រភេទ នៃការវិនិយោគដែលត្រូវបានធ្វើ គោលនយោបាយកសិកម្ម និងឧស្សាហកម្មដែលនឹងត្រូវបានអនុម័ត និងថាតើយើង នឹងមានភាពល្អប៉ុណ្ណាក្នុងការពង្រីក វិស័យសេវាកម្ម។

ជារួមខណៈដែលទីផ្សារការងារ និងការព្រួយបារម្ភពីសេដ្ឋកិច្ចគួរតែមានសេណារីយ៉ូមួយ ការសម្របសម្រួលដ៏សមស្រប និងបន្តជានិរន្តគួរតែត្រូវបានបង្កើតឡើងផងដែររវាងការរៀបចំ និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច ហើយនិងការរៀបចំនិងការអនុវត្តគោលនយោបាយបណ្តុះបណ្តាល គួរតែត្រូវបានកំណត់ឱ្យបានទូលំទូលាយ។


**ទំនាក់ទំនង:**

**គីម សុខនីន**

Email: soknin.kim14@gmail.com , Phone: 012 621 337

នាយកដ្ឋានព័ត៌មានទីផ្សារការងារ , ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ